**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 03-Mar-2020, 10:14
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ:**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: សាធារណៈ:/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អោ អាន**
លោក មុំ លុដ្ឋ
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

## I. សារណា

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សុំឆ្លើយតបទៅនឹងចម្លើយតបរបស់ អោ អាន[1] ទៅនឹងសំណើរបស់គាត់ដែលសុំឲ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ" ឬ "អង្គជំនុំជម្រះ) ចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ")[2]។ ជារួម អោ អាន កំណត់ប្រភេទសំណើរបស់ ស.ព.អ មិនត្រឹមត្រូវថាជាសំណើសុំឲ្យធ្វើការពិចារណាឡើងវិញ ខកខានមិនបានយល់ថា វិធាន ៧៧(១៣)(ខ) មានអនុភាពលុបលើវិធាន ៧៧(១៣)(ក) បានតវ៉ាមិនត្រឹមត្រូវថា ចំនួនភាគច្រើនធម្មតាគួរតែមានអានុភាពលុបលើគោលជំហរស្វ័យប្រវត្តិដែលជាមូលដ្ឋាននៃប្រព័ន្ធច្បាប់ អ.វ.ត.ក យល់ច្រឡំចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio reo*) និងបកស្រាយខុសចំពោះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា និងមូលដ្ឋានដ៏មានកម្រិតសម្រាប់ការរំលត់រឿងក្តីនៅ អ.វ.ត.ក។

2. អោ អាន បានកំណត់ប្រភេទសំណើរបស់ ស.ព.អ ខុស ថាជាការស្នើសុំឲ្យ អ.ប.ជ "ពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញលើអានុភាពផ្លូវច្បាប់ និងផលវិបាកផ្នែកនីតិវិធីនៃដីកាដំណោះស្រាយពីរផ្ទុយគ្នា"[3]។ ទោះជាយ៉ាងណា នេះមិនមែនជាសេចក្តីសម្រេចដែល អ.ប.ជ ធ្លាប់បានធ្វើនោះទេ។ ផ្ទុយទាំងស្រុងទៅនឹងមូលដ្ឋាននៃអំណះអំណាងរបស់គាត់ អោ អាន បានលើកឡើងយ៉ាងត្រឹមត្រូវនៅត្រង់កន្លែងផ្សេងទៀត[4]ថា អង្គជំនុំជម្រះមិនអាចទទួលបានសំឡេងភាគច្រើនលើសលុបដើម្បីបញ្ជាក់អានុភាពនៃសេចក្តីសម្រេចជាឯកច្ឆ័ន្ទរបស់ខ្លួនថា *ការចេញ* ដីកាដំណោះ

[1] ឯកសារ **D359/26** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ("ចម្លើយតបរបស់ អោ អាន") ដែលបានដាក់ជាភាសាអង់គ្លេសពីដំបូងសិន ដោយមានការបកប្រែជាភាសាខ្មែរតាមក្រោយ។ ចាប់ពីកាលបរិច្ឆេទនៃការដាក់ឯកសារនេះមក ការបកប្រែជាភាសាខ្មែរនៅពុំទាន់បានជូនដំណឹងនៅឡើយទេ។

[2] ឯកសារ **D359/25** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើរបស់ ស.ព.អ"), បានជូនដំណឹងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

[3] *សូមមើល ឧ.ទា* ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១ (មានការដកស្រង់), កថាខណ្ឌ ២១ (ដោយការកំណត់ប្រភេទ "សេចក្តីសម្រេច" របស់ អ.ប.ជ ថា "នៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ និងអានុភាពអង្គច្បាប់នៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា")។

[4] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២, ២១, ២២, ២៤, ២៦។

ស្រាយពីរផ្ទុយគ្នាគឺខុសច្បាប់នោះទេ[5]។ តាមពិតនោះ ចៅក្រមបានពិចារណាដាច់ដោយឡែកពីគ្នាអំពីនីត្យានុកូលភាពនៃដីកាដំណោះស្រាយ*នីមួយៗ*[6]។ ក្របខណ្ឌច្បាប់ អ.វ.ត.ក ចែងអំពីផលវិបាកនៃស្ថានភាពនេះ ហើយនីតិវិធីទាំងអស់នេះដែលត្រូវតែអនុវត្តតាម។

3. ដោយសារតែ អ.ប.ជ មិនបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ[7] ដោយសំឡេងភាគច្រើនលើសលុបនោះ អ.ជ.ស.ដ ត្រូវតែទទួលយកអនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង[8] ហើយរឿងក្ដីនេះនឹងត្រូវបញ្ជូនទៅជំនុំជម្រះ បើទោះជាដីកាសម្រេចលើកលែងចោទប្រកាន់[9]មិនត្រូវបានបដិសេធក៏ដោយ[10]។ ចំណុចនេះត្រូវបានកំណត់ដោយវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលជា*វិធានពិសេស (lex specialis)* ទាក់ទងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយហេតុដូច្នេះ លុបលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក) ដែលទាក់ទងទៅនឹងដីកា

---

[5] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ) កថាខណ្ឌ ៥៤, ៨៩, ៩៨, ១០២, ១២៤, ផ្នែកសម្រេចសេចក្ដី ត្រង់ KH 01634854 (ជាឯកច្ឆន្ទ)។

[6] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ៨៩, ១២៤ (ជាឯកច្ឆន្ទ) កថាខណ្ឌ ១៧០-៣០២ (យោបល់ចៅក្រមជាតិ) កថាខណ្ឌ ៣០៤-៣២៩, ៦៨១ (យោបល់ចៅក្រមអន្តរជាតិ)។

[7] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)។

[8] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដូចដែលបានធ្វើវិសោធនកម្មនៅ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង” ឬ “វិធាន”)។ វិធាន ៧៧(១៣)(ខ) បង្ហាញថា កាលណាបណ្ដឹងឧទ្ធរណ៍មួយប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានតម្កល់នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍នោះទេ គោលជំហរស្វ័យប្រវត្តិ គឺថាត្រូវប្ដឹងទៅ អ.ជ.ស.ដ ដោយឈរលើមូលដ្ឋាននៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ វិធាន ៧៩(១) ចែងថា អ.ជ.ស.ដ ត្រូវបានប្ដឹងឱ្យទទួលយកដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស ឬ តាមសេចក្ដីសម្រេចរបស់ អ.ប.ជ ដោយរួមជាមួយនឹងវិធាន ១(២) ដែលកំណត់និយមន័យ ស.ច.ស ថាជាការបំពេញកិច្ចរួមគ្នា ឬ ដាច់ដោយឡែកពីគ្នា។

[9] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាសម្រេចលើកលែងចោទប្រកាន់”)។

[10] *ផ្ទុយពីនេះ* ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៣, ២៥ ស.ព.អ មិនបានមើលរំលងអង្គហេតុដែលថា ដីកាសម្រេចលើកលែងចោទប្រកាន់ មិនត្រូវបានបដិសេធនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ទេ។ គាត់មិនបានលើកឡើងអំពីវានៅក្នុងសំណើររបស់គាត់ទេ ពីព្រោះវិធាន ៧៧(១៣)(ខ) មានអានុភាពលុបលើ។

"ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[11]។ "ដីកាសម្រេចលើកលែងចោទប្រកាន់" និង "ដីកាដំណោះស្រាយ" ដូច "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" គឺជាពាក្យពេចន៍ដែលត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង[12]។ ប្រសិនបើអ្នកកាត់តែងវិធានមានបំណងលើកឡើងជាក់លាក់អំពីអានុភាពនៃការបរាជ័យរបស់ អ.ប.ជ ក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នោះ ច្បាស់ណាស់ពួកគេពិតជាអាចបានធ្វើដូច្នោះ ប៉ុន្តែបានជ្រើសរើសមិនធ្វើដូច្នោះទេ។ ផ្ទុយទៅវិញ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងអនុវត្តចេតនាផ្ទាល់របស់អង្គការសហប្រជាជាតិ ("អ.ស.ប") និងរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលពួកគេសន្និដ្ឋានបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក[13]។ ចេតនានេះក៏ត្រូវបានបញ្ជាក់ផងដែរនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ដែលចែងថា នៅពេលដែលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត

---

[11] ពាក្យឡាតាំង "វិធានពិសេស (lex specialis)" សំដៅលើលទ្ធិពាក់ព័ន្ធទៅនឹងការបកស្រាយច្បាប់ ដែលតាមរយៈលទ្ធិនេះ ច្បាប់ដែលគ្រប់គ្រងលើអង្គសេចក្តីជាក់លាក់មួយ (*lex specialis*) លុបលើច្បាប់មួយដែលគ្រាន់តែគ្រប់គ្រងលើបញ្ហាទូទៅ (*វិធានទូទៅ (lex generalis)*)។

[12] *សូមមើល* វិធានផ្ទៃក្នុង ទំព័រ ៨៣-៨៤។

[13] ឯកសារ **D324.30** លិខិតពីអគ្គលេខាធិការ អ.ស.ប ចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ចំណារដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ពីលោក Hans Corell ទៅកាន់លោកអគ្គលេខាធិការ ប្រធានបទ៖ សេចក្តីអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសដើម្បីដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01326090 (នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជាលើកដំបូងនូវមាត្រា ៧(៤) ដែលសរសេរទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell អគ្គលេខាធិការរងទទួលបន្ទុកផ្នែកកិច្ចការច្បាប់ និងក្រុមប្រឹក្សាច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាមួយជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានក្រុមចរចាររបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការច្រានចោលនូវការអំពាវនាវរបស់គាត់ឲ្យមានលក្ខខណ្ឌតម្រូវមតិភាគច្រើនដាច់ខាត ដើម្បី*អនុម័តិឲ្យមាន* ការបន្តការស៊ើបសួរ ឬការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានព្រាងនេះមានន័យថា "អ្នកត្រូវការមតិភាគច្រើនដាច់ខាត ដើម្បីបញ្ឈប់ការស៊ើបសួរ ឬការចោទប្រកាន់")។ ឯកសារ **D324.36** សេចក្តីថ្លែងការណ៍ដោយលោក Hans Corell អគ្គលេខាធិការរង នៅពេលដែលចាកចេញពីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ EN 01326112។ *សូមមើលផងដែរ* ឯកសារ **D359/3/1.1.43** លោក David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយលើកទី៣ វ៉ូលូមIII ឆ្នាំ២០០៨ ទំព័រ២៤៦ (EN 01598756) (លោក David Scheffer ដែលជាឯកអគ្គរដ្ឋទូតគោចររបស់ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងបានចូលរួមយ៉ាងច្រើននៅក្នុងកិច្ចចរចារ អ.វ.ត.ក បានបញ្ជាក់ទស្សនៈដូចគ្នាថា៖ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបសួរត្រូវបាន*បញ្ឈប់* នោះគឺ ប្រសិនបើ [អ.ប.ជ] សម្រេចដោយសំឡេងភាគច្រើនលើសលុបថាវាគួរតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះគឺថា វារារាំងមិនឲ្យ [ស.ច.ស] ឬ សហព្រះរាជអាជ្ញាណាម្នាក់រាំងខ្ទប់ដល់ការស៊ើបសួរ ឬ ការចោទប្រកាន់ណាមួយ ដោយការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាមួយជាមួយនឹងដៃគូរបស់ខ្លួន ឬក៏ ដោយគ្រាន់តែបង្អាក់ការស៊ើបសួរ ឬការចោទប្រកាន់ បណ្តាលមកពីឥទ្ធិពលនយោបាយ ឬឥទ្ធិពលប្រភេទផ្សេងៗទៀត" (គូសបញ្ជាក់បន្ថែម))។

("ស.ច.ស") ខ្វែងយោបល់គ្នាលើការបន្តដំណើរការរឿងក្តីទៅមុខ រឿងក្តីនោះត្រូវបន្តទៅដំណាក់កាលបន្ទាប់ទៀតបើសិនណាជាគ្មានសំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ប.ជ ក្នុងការរារាំងដំណើរការទៅមុខរបស់វាទេនោះ[14]។ សំណើរបស់ ស.ព.អ គ្រាន់តែស្នើសុំធម្មតាឲ្យចៅក្រម អ.ប.ជ អនុវត្តភាសាធម្មតានៃច្បាប់ និងវិធាន ដែលពួកគាត់ជាប់កាតព្វកិច្ច ដោយការចាត់វិធានការ*រដ្ឋបាល*ជំហានចុងក្រោយដើម្បីបញ្ជូនសំណុំរឿង004/២ (រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

4. ផ្ទុយទៅវិញ អោ អាន បង្កើតខុសនូវ "គោលជំហរស្វ័យប្រវត្តិ" ថ្មីមួយ ដែលមិនត្រូវបានរំពឹងទុកដោយក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដោយបានលើកឡើងថា ក្នុងពេលអវត្តមានសំឡេងភាគច្រើនលើសលុប ទស្សនៈសំឡេងភាគច្រើនធម្មតាដែលបានតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលុបលើ និងអះអាងថា ការបន្តកិច្ចដំណើរការនីតិវិធីនឹងរំលោភលើ "និយាមនីតិវិធីត្រឹមត្រូវជាមូលដ្ឋាន" និងជា "ការប្រមាថចំពោះតុលាការដែលបង្កើតឡើងដោយច្បាប់"[15]។ ការពឹងផ្អែករបស់ អោ អាន លើទស្សនៈសំឡេងភាគច្រើនគឺមិនត្រឹមត្រូវឡើយ ដោយយោងទៅលើលក្ខណៈកូនកាត់ និងរចនាសម្ព័ន្ធពិសេសរបស់ អ.វ.ត.ក។ ទស្សនៈសំឡេងភាគច្រើនធម្មតាមិនមានទម្ងន់ជាកត្តាកំណត់នៅ អ.វ.ត.ក ដូចដែលវាមាននៅតុលាការផ្សេងទៀតនោះទេ។ ផ្ទុយទៅវិញ អ្នកបង្កើតតុលាការនេះ បានអនុវត្តវិធានស្តីពីសំឡេងភាគច្រើនលើសលុប ដើម្បីការពារកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងឥទ្ធិពល ឬការជ្រៀតជ្រែកពីខាងក្រៅ និងបានបង្កើតគោលជំហរស្វ័យប្រវត្តិនេះឡើង ដើម្បីឲ្យរឿងក្តីមួយអាចមិនត្រូវបានគេបង្អាក់ ប្រសិនបើសំឡេងភាគច្រើនលើសលុបមិនអាចរកបានទេនោះ[16]។ វិធានស្តីពីសំឡេងភាគច្រើនលើសលុប និងគោលជំហរស្វ័យប្រវត្តិនេះ ត្រូវបានព្រមព្រៀងគ្នាដោយ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា

---

[14] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២00៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៧(៤)។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២00៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ថ្មី។

[15] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២៧។ *សូមមើលផងដែរ* កថាខណ្ឌ ៣, ២៤, ២៥។

[16] *សូមមើល ឧទា.* ឯកសារ **D359/3/1.1.43** លោក David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយលើកទី៣ វ៉ុលុមIII ឆ្នាំ២00៨ ទំព័រ២៤៦ (EN 01598756)។

និងបានអនុវម័តិជាច្បាប់[17]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ អោ អាន ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ត្រឹមត្រូវតាមច្បាប់ទាំងអស់នេះ មិនបានធ្វើឲ្យតុលាការនេះក្លាយទៅជាតុលាការអសមត្ថភាពនោះទេ។

5. អោ អាន អះអាងមិនត្រឹមត្រូវថា ដោយហេតុថា ស.ច.ស ខកខានមិនបានដាក់ការខ្វែងយោបល់របស់ខ្លួនទៅ អ.ប.ជ ដោយប្រើនីតិវិធីដោះស្រាយការខ្វែងយោបល់តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ស.ច.ស ជាធរមាន "បានជ្រើសយកការមិនចូលរួម" ក្នុងគោលជំហរស្វ័យប្រវត្តិនេះ ដែលបានធ្វើឲ្យវាមិនអាចអនុវត្តបានចំពោះរឿងក្ដីនៅពេលនេះ[18]។ ខណៈដែលអង្គជំនុំជម្រះនេះ*ពិត*ជាបានរកឃើញថា ស.ច.ស បានខកខានមិនបានបញ្ជូនការខ្វែងយោបល់របស់ខ្លួនទៅកាន់ អ.ប.ជ[19] អង្គជំនុំជម្រះក៏បានពិនិត្យមើលថាតើ ការខកខាននោះបានរារាំងអានុភាពជាក់ស្ដែងនៃគោលជំហរស្វ័យប្រវត្តិ ដែលជាមូលដ្ឋាននៃប្រព័ន្ធច្បាប់ អ.វ.ត.ក ទាំងមូល ឬយ៉ាងណា[20]។ ចៅក្រមទាំងអស់ទាំងប្រាំនាក់នៃ អ.ប.ជ បានសង្កត់ធ្ងន់ថា "គោលការណ៍ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្ដែង មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្ដាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនេះ ក្លាយទៅជាគ្មានន័យនោះទេ"[21]។ តាមរយៈសំអាងហេតុនេះ ទោះបីជា អ.ប.ជ ជាចុងក្រោយបានរកឃើញថា ការចេញដីកាដំណោះស្រាយពីរខ្វែងគ្នារបស់ ស.ច.ស គឺខុសច្បាប់ក៏ដោយ ក៏គោលជំហរស្វ័យប្រវត្តិគឺជាគោលការណ៍ "ជាមូលដ្ឋាន និងជាកត្តាកំណត់" ដែលវាមិនអាចត្រូវបានលុបលើដោយសកម្មភាពខុសច្បាប់របស់ ស.ច.ស ឡើយ។

6. អោ អាន ក៏យល់ច្រឡំអំពីគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*ផងដែរ[22]។ អត្ថិភាពនៃគោលជំហរស្វ័យប្រវត្តិផ្ទុយទៅនឹងការអះអាងរបស់ អោ អាន ថា

[17] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។

[18] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២២ និង ២៣ *ដោយបានយោង* ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ កថាខណ្ឌ ១២១។

[19] *សូមមើល ឧទា.* ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១២០។

[20] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១១២។

[21] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១១២ គូសបញ្ជាក់បន្ថែម។

[22] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤, ២៦។

"ការជាប់គាំង និងភាពមិនច្បាស់លាស់ទាំងអស់ត្រូវតែដោះស្រាយក្នុងប្រយោជន៍ [របស់គាត់]"[23]។ ជាងនេះទៀត គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស និងជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែរកឱ្យឃើញហួសពីវិមតិសង្ស័យ *នៅពេលជំនុំជម្រះ*[24]។ គោលការណ៍នេះត្រូវបានអនុវត្តនៅពេលដែលការសង្ស័យផ្នែកអង្គហេតុមិនត្រូវបានលុបបំបាត់ដោយភ័ស្តុតាង ដែលបង្ហាញនៅពេលជំនុំជម្រះ ឬនៅក្នុងករណីកម្រមាននៃការសង្ស័យនៅក្នុងច្បាប់ *សារធាតុ*[25]។ ម្យ៉ាងវិញទៀត គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ទាក់ទងទៅនឹងការសង្ស័យអំពីពិរុទ្ធភាពចុងក្រោយរបស់ជនជាប់ចោទ មិនមែនការជាប់គាំងផ្នែកនីតិវិធីនៅក្នុងដំណាក់កាលមុនពេលជំនុំជម្រះ ដែលមិនទាក់ទងទៅនឹងការសម្រេចណាមួយអំពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធនោះទេ[26]។

---

[23] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២៦។

[24] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ (សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន) កថាខណ្ឌ ៣១។ *រដ្ឋអាជ្ញា ទល់នឹង Limaj និងគូកន* សំណុំរឿង IT-03-66-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១។ *Renzaho ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿង ICTR-97-31-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ (កត់សម្គាល់ថា គោលការណ៍នេះអនុវត្តចំពោះការរកឃើញនានាដែលត្រូវការសម្រាប់ការកាត់ទោស)។ *រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន* សំណុំរឿង IT-96-21-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ("សាលក្រម *Čelebići*") កថាខណ្ឌ ៦០១ ("នៅចុងបញ្ចប់នៃសំណុំរឿង ជនជាប់ចោទត្រូវមានសិទ្ធិទទួលបានប្រយោជន៍ពីការសង្ស័យនេះ ថាតើបទល្មើសត្រូវបានបញ្ជាក់ភ័ស្តុតាង ឬយ៉ាងណា")។

[25] *សូមមើល ឧទា.* លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ មាត្រា ២២(២)។ *សូមមើលបន្ថែមទៀត រដ្ឋអាជ្ញា ទល់នឹង Gbagbo និង Blé Goudé* សំណុំរឿង ICC-02/11-01/15-744 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Laurent Gbagbo និងលោក Charles Blé Goudé ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី I ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ក្រោមចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំដាក់បញ្ចូលសក្ខីកម្មដែលបានកត់ត្រាពីមុន ក្រោមវិធាន ៦៨(២)(ខ) និង ៦៨(៣)" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៣។

[26] *សូមមើល ឧទា.* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ៨៥ ("ទោះបីជានៅដំណាក់កាលមុនអង្គសេចក្តីមានភាពចាំបាច់ត្រូវមានលក្ខខណ្ឌលើសពីសូចនាករបញ្ជាក់ ឬ ភាពមន្ទិលសង្ស័យដើម្បីបញ្ជូនជនម្នាក់ទៅជំនុំជម្រះបានក៏ដោយ ភស្តុតាងដែលប្រមូលបានពុំទាន់ចាំបាច់ត្រូវបញ្ជាក់ពីពិរុទ្ធភាពឱ្យបានជាក់លាក់នៅឡើយនោះទេ") កថាខណ្ឌ ១៦៣ (ជាឯកផ្ជូន)។ សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣២៣។

7. គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*ត្រូវបានអនុវត្តយូរៗម្តងក្នុងពេលមានភាពមិនច្បាស់លាស់នៃច្បាប់ ប៉ុន្តែភាពអាចអនុវត្តបានរបស់វាត្រូវបានកំណត់ត្រឹមការសង្ស័យដែលនៅសេសសល់បន្ទាប់ពីការប្រើវិធាននៃការបកស្រាយច្បាប់ស៊ីវិល[27]។ រាល់អត្ថបទច្បាប់ត្រូវស្ថិតក្រោមការបកស្រាយ ហើយអង្គហេតុដែលថាសេណារីយ៉ូជាក់លាក់មួយអាចមិនត្រូវបានគ្របដណ្តប់ដោយវានោះ មិននាំឱ្យមាន "ការសង្ស័យ" ដែលតាមរយៈការសង្ស័យនេះចុងចោទនឹងតែងតែទទួលបានអត្ថប្រយោជន៍ជានិច្ចនោះទេ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចថា "ហេតុដូច្នេះ [...] គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ"[28]។

8. ខណៈដែលគោលជំហររបស់ ស.ព.អ គឺថា មិនមាន*ភាពខ្វះចន្លោះនៃច្បាប់* ត្រូវបានបង្ហាញនៅក្នុងរឿងក្តីនេះ ដោយហេតុថា គោលជំហរស្វ័យប្រវត្តិអាចអនុវត្តបានយ៉ាងច្បាស់លាស់ នៅពេលដែលបញ្ហានីតិវិធីមិនត្រូវបានដោះស្រាយដោយវិធានផ្ទៃក្នុង វិធាន ២ នៃវិធានផ្ទៃក្នុង ណែនាំអង្គជំនុំជម្រះឱ្យសម្រេចលើបញ្ហានោះដោយប្រកាន់ខ្ជាប់ទៅនឹងច្បាប់កម្ពុជា និងវិធាននីតិវិធីដែលពាក់ព័ន្ធ។ វិធានពាក់ព័ន្ធទាំងនេះរួមបញ្ចូលទាំងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលកំណត់ថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[29]។ កត់សម្គាល់ថា វិធាន ២ មិនផ្តល់ឱ្យមានការសន្និដ្ឋានជាស្វ័យប្រវត្តិក្នុងប្រយោជន៍ដល់ជនជាប់ចោទនោះទេ។ ផ្ទុយទៅវិញ វិធាននេះណែនាំអង្គជំនុំជម្រះឱ្យផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋាន ដែលមានចែងនៅក្នុងវិធាន ២១ ដែលការពារសិទ្ធិ មិនមែនតែសិទ្ធិរបស់ជនជាប់ចោទទេ ប៉ុន្តែថែមទាំងសិទ្ធិ

---

[27] សំណុំរឿង00២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន កថាខណ្ឌ ៣១ (បានពន្យល់ថាវិធានប្រព័ន្ធច្បាប់ស៊ីវិលនៃការបកស្រាយច្បាប់ត្រូវពិចារណាលើ "ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ")។ សាលក្រម *Čelebići* កថាខណ្ឌ ៤១៣ ("អានុភាពនៃការបង្កើតឡើងយ៉ាងហ្មត់ចត់នៃបទប្បញ្ញត្តិនៃលក្ខន្តិកៈព្រហ្មទណ្ឌនេះ គឺថា កាលណាមានពាក្យពេចន៍មួយដែលមានមន្ទិលសង្ស័យ ឬ ប្រយោគដែលមិនច្បាស់លាស់ បន្សល់ទុកឱ្យមានការសង្ស័យដ៏សមហេតុសមផលមួយចំពោះនិយមន័យរបស់វា *ដែលវិធានដែលប្រើដើម្បីបកស្រាយបរាជ័យក្នុងការដោះស្រាយ* ផលប្រយោជន៍នៃការសង្ស័យនេះ ត្រូវបានផ្តល់ទៅឱ្យបុគ្គលនោះ ហើយប្រឆាំងនឹងអង្គនីតិបញ្ញត្តិដែលខកខានមិនបានពន្យល់ខ្លួនវាផ្ទាល់។ នេះគឺជាមូលហេតុដែលលក្ខន្តិកៈព្រហ្មទណ្ឌដែលមិនច្បាស់លាស់ ត្រូវបកស្រាយ*ប្រឆាំងទៅនឹងអ្នកព្រាង*" (គូសបញ្ជាក់បន្ថែម))។

[28] សំណុំរឿង00២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន កថាខណ្ឌ ៣១។

[29] វិធាន ២ នៃវិធានផ្ទៃក្នុង។

របស់ជនរងគ្រោះផងដែរ និងកំណត់ឲ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ ដែលរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី *ទាំងអស់*។ ដើម្បី "ដោះស្រាយភាពជាប់គាំង និងភាពមិនច្បាស់លាស់ទាំងអស់" ក្នុងប្រយោជន៍របស់ អោ អាន ដូចដែលគាត់អះអាងថាតម្រូវឲ្យធ្វើនោះ[30] នឹងធ្វើឲ្យខូចតុល្យភាពនេះ ជាពិសេសការចូលរួមដ៏មានអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនានា អនុលោមតាមការស្វែងរកឲ្យមានការផ្សះផ្សារជាតិរបស់ អ.វ.ត.ក[31]។

9. ជាចុងក្រោយ អោ អាន បកស្រាយខុសចំពោះវិធាន ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដោយអះអាងទាំងខុសថា មាត្រានេះកំណត់ថា រឿងក្តី០០៤/២ ត្រូវបានរំលត់យ៉ាងមានប្រសិទ្ធិភាពត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[32]។ ក្នុងភាសាខ្មែរ មាត្រា ៣៨ ចែងថា៖ "*វិមតិសង្ស័យ*ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[33] មិនមែនដូច អោ អា អះអាងថា ការសង្ស័យ*ណាមួយ* នោះទេ[34]។ ការប្រើពាក្យ "វិមតិសង្ស័យ" របស់រដ្ឋធម្មនុញ្ញនេះគាំទ្រគោលជំហររបស់ ស.ព.អ ដែលថា *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តជាចំបងតែនៅពេលដែលការសង្ស័យនៅតែមានក្រោយពេលវាយតម្លៃអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ*នៅពេលជំនុំជម្រះ* ដោយសារតែដំណាក់កាលជំនុំជម្រះគឺជាដំណាក់កាលតែមួយគត់ នៅពេលដែលបន្ទុកនៃការបង្ហាញភស្តុតាងគឺហួសពី "វិមតិសង្ស័យ"។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគាំទ្របន្ថែមទៀតលើគោលជំហរនេះ ថា "វិមតិសង្ស័យ" និង "ប្រយោជន៍នៃការសង្ស័យ" ត្រូវបានប្រើតែក្នុងបរិបទនៃពិរុទ្ធភាពរបស់ជនដែលត្រូវបានកាត់ទោសតែប៉ុណ្ណោះ[35]។

---

[30] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២៦។

[31] សំណុំរឿង០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៤-៦៥។ កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា។

[32] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤, ៥, ១៨។

[33] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តិថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣៨ (គូសបញ្ជាក់បន្ថែម)។

[34] *ផ្ទុយពី* ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១៨។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ("ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា") មាត្រា ៣៥០-៣៥១ (ទាក់ទងទៅនឹងការប្រកាសពីពិរុទ្ធភាព ដោយកត់សម្គាល់ថា "វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច") មាត្រា ៤៤៥ ("បណ្តឹងសើរើរឿងក្តីអាចធ្វើបានតែនៅក្នុងករណី៖ [...] ៤-កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មីដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត")។

10. អំណះអំណាងអំពីការរំលត់រឿងក្តីរបស់ អោ អាន[36] ក៏រំលោភលើច្បាប់នីតិវិធីរបស់កម្ពុជា (និងបារាំង) ផងដែរ។ នីតិវិធីកម្ពុជាចែងថា បណ្តឹងអាជ្ញាអាចត្រូវបានរំលត់តែនៅពេលមរណភាពរបស់ជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ ឬ*អាជ្ញាអស់ជំនុំ* តែប៉ុណ្ណោះ[37]។ យុត្តិសាស្ត្រនៅកម្រិតអន្តរជាតិ[38] ក៏បង្កើតចំណុចចាប់ផ្តើមអប្បរមាខ្ពស់បំផុតសម្រាប់ការរំលត់ ឬផ្អាកកិច្ចដំណើរការនីតិវិធី[39]។ អ.ជ.ត.ក និង អ.ជ.ស.ជ ទាំងពីរនេះបានសម្រេចថា ដូច្នេះមានន័យថា អ.វ.ត.ក មិនមានសិទ្ធិអំណាចបង្គាប់ឱ្យមានការរំលត់បណ្តឹងអាជ្ញាដោយមូលហេតុផ្សេងពីនេះបានទេ[40]។ តាមពិតនោះ តាមវិធាន ៦៧(៣) នៃ

[36] ឯកសារ **D359/26** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៣-៥។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ មាត្រា ៦ ("L'action publique pour l'application de la peine s'éteint par la mort du prévenu, la prescription, l'amnistie, l'abrogation de la loi pénale et la chose jugée."។ ការបកប្រែក្រៅផ្លូវការ៖ ("កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានរំលត់ដោយមរណភាពរបស់ចុងចោទ ដោយការផុតអាជ្ញាយុកាល ដោយការលើកលែងទោស ដោយនិរាករនៃច្បាប់ព្រហ្មទណ្ឌ និង ដោយអាជ្ញាអស់ជំនុំ")។

[38] ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី ណែនាំថា ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

[39] ការរំលត់ ឬ ការផ្អាកកិច្ចដំណើរការនិតិវិធីម្តងម្កាលត្រូវបានអនុញ្ញាតឱ្យដោយតុលាការអន្តរជាតិផ្សេងៗទៀត ក៏ប៉ុន្តែឧទាហរណ៍គឺកម្រមានណាស់ ហើយវាឆ្លុះបញ្ចាំងពីស្ថានភាព ដែលនៅក្នុងនោះ ការមិនបន្តត្រូវបានពិចារណាថា គឺជាដំណោះស្រាយមួយ*តែគត់* ដែលអាចធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬបើមិនដូច្នោះទេ វាមាន សំខាន់ខ្លាំងសម្រាប់ផលប្រយោជន៍នៃយុត្តិធម៌។ *សូមមើល ឧទា. រដ្ឋអាជ្ញា ទល់នឹង* Karadžić សំណុំរឿង IT-95-5/18-T សេចក្តីសម្រេចលើញត្តិស្នើសុំការផ្អាកកិច្ចដំណើរការនិតិវិធី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៤ (ដោយទទួលស្គាល់ថាដំណោះស្រាយដ៏កម្រនៃការផ្អាកកិច្ចដំណើរការនិតិវិធី អាចនឹងត្រូវបានអនុញ្ញាត កាលណាការបំពានលើសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងររបស់ជនជាប់ចោទ នាំឱ្យមានដំណើរការកាត់សេចក្តីដ៏ត្រឹមត្រូវមួយមិនអាចធ្វើទៅបាន)។ *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo* សំណុំរឿង ICC-01/04-01/06-772 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ ដោយអនុលោមតាមមាត្រា ១៩(២)(ក) នៃច្បាប់លក្ខន្តិកៈថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

[40] សំណុំរឿង០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ អ.ជ.ត.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) អ.ជ.ស.ជ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧ (ដោយរកឃើញថាកិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក អាចគ្រាន់តែត្រូវបានរំលត់តាមវិធាន៨៩(១)(ខ) នៃវិធានផ្ទៃក្នុង

វិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិណាឲ្យលើកលែងចោទប្រកាន់នៅដំណាក់កាលដីកាដំណោះស្រាយ ដោយសារតែការជាប់គាំងផ្នែកនីតិវិធីនោះទេ។

## II. ដំណោះស្រាយដែលស្នើឡើង

11. សាស្រ័យលើមូលហេតុដែលបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិសុំស្នើឲ្យអង្គបុរេជំនុំជម្រះចាត់វាល់វិធានការរដ្ឋបាលចាំបាច់ ដើម្បីធានាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្តី00៤/២ (អោ អាន) និងឯកសារសំណុំរឿងសេសសល់ ត្រូវបានបញ្ជូនជាបន្ទាន់ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ | **លោកស្រី** **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and stamp: CO-PROSECUTORS CO-PROCUREURS E.C.C.C * C.E.T.C] |



ផ្អែកលើទឡ្ហីករណ៍មួយក្នុងចំណោមទឡ្ហីករណ៍ដ៏មានកម្រិត ដែលមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។